00877460

E238/12/1/1

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 01 / 2013
ម៉ោង (Time/Heure): 13:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

សាធារណៈ / Public

# អនុស្សរណៈ - អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១៣

**ជូនចំពោះ:** គ្រប់ភាគីទាំងអស់ក្នុងសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សំណើរបស់ អៀង សារី សុំឲ្យកែប្រែអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលផ្ញើជូនក្រុមគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំគាត់នៅក្នុងមន្ទីរឃុំឃាំង អ.វ.ត.ក (ឯកសារ E238/12/1)

១. នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ដល់ក្រុមគ្រូពេទ្យដែលទទួលភារកិច្ចពិនិត្យ ព្យាបាល និងថែទាំសុខភាព អៀង សារី ឲ្យរាយការណ៍ជារៀងរាល់ថ្ងៃ និងដោយផ្ទាល់មកអង្គជំនុំជម្រះសាលាដំបូងមុនពេលចាប់ផ្តើមសវនាការរៀងរាល់ព្រឹក ហើយបើចាំបាច់ក្នុងពេលណាមួយនៅពេលរសៀល។ របាយការណ៍គួរតែបញ្ចូលតែការប្រែប្រួលសំខាន់ៗនៃស្ថានភាពសុខភាពរបស់ អៀង សារី ដែលខុសពីសេចក្តីសន្និដ្ឋាននៅក្នុងរបាយការណ៍របស់អ្នកជំនាញតែប៉ុណ្ណោះ (ឯកសារ E238/4)។ ជាងនេះទៀត ប្រសិនបើក្រុមគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និង ថែទាំសុខភាពជនជាប់ចោទមានការសង្កេតផ្សេងៗទាក់ទងនឹងសម្ភារៈបរិក្ខារដែលបំពាក់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដែលអាចជួយបង្កើនសមត្ថភាពរាងកាយរបស់ អៀង សារី ក្នុងពេលចូលរួមសវនាការនោះ សូម បញ្ចូលការសង្កេតទាំងនេះនៅក្នុងរបាយការណ៍របស់ខ្លួនផងដែរ (ឯកសារ E238/12)។

២. នៅថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១៣ អង្គជំនុំជម្រះបានទទួលសំណើបន្ថែមពីមេធាវីការពារក្តី អៀង

សារី (ឯកសារ E238/12/1) ដែលស្នើសុំអង្គជំនុំជម្រះសាលាដំបូង៖

ក. ណែនាំមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ឱ្យចាត់តាំងអ្នកជំនាញវេជ្ជសាស្ត្រដែលមានគុណវុឌ្ឍិដើម្បីធ្វើការវាយតម្លៃប្រចាំថ្ងៃជាបន្តបន្ទាប់ចំពោះសមត្ថភាពរបស់ អៀង សារី ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី នៅពេលគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ ឬម្យ៉ាងទៀត

ខ. បង្គាប់ឱ្យគ្រូពេទ្យដែលកំពុងពិនិត្យ ព្យាបាល និងថែទាំ អៀង សារី បច្ចុប្បន្នផ្តល់នូវព័ត៌មានឱ្យបានច្បាស់លាស់ទាក់ទិននឹងស្ថានភាពនានាដែលអាចប៉ះពាល់ដល់សមត្ថភាពរបស់គាត់ក្នុងការតាមដានកិច្ចដំណើរការនីតិវិធី និងជាពិសេសស្នើសុំឱ្យក្រុមគ្រូពេទ្យទាំងនោះ៖

(១) បញ្ចូលនៅក្នុងរបាយការណ៍របស់ខ្លួននូវកម្រិតនៃលទ្ធភាពដែល អៀង សារី អាចតាមដានកិច្ចដំណើរការនីតិវិធីនៅពេលគាត់វិលមុខ ងងុយគេង ឈឺចុកចាប់ ឬឈឺចាប់ដោយសារស្ថានភាពផ្សេងទៀត។

(២) រៀបរាប់ពិស្តារនៅក្នុងរបាយការណ៍របស់ខ្លួននូវកត្តានានាដែលនាំឱ្យ អៀង សារី វិលមុខ ឬសម្រាន្តលក់នៅពេលសវនាការ ឬឈឺចុកចាប់។ និង

(៣) បញ្ចូលក្នុងរបាយការណ៍របស់ខ្លួននូវអ្វីដែលក្រុមគ្រូពេទ្យយល់ថា ពាក់ព័ន្ធនឹងសមត្ថភាពផ្លូវកាយ ឬផ្លូវចិត្តរបស់ អៀង សារី ក្នុងការចូលរួមក្នុងកិច្ចដំណើរការនីតិវិធី (មិនកម្រិតត្រឹមតែការប្រែប្រួល "សំខាន់ៗ" ទេ)។

៣. គិតមកដល់ត្រឹមថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១២ ជនជាប់ចោទ អៀង សារី ត្រូវបានសន្និដ្ឋានថាមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការបាន (ឯកសារ E238/9)។ សេចក្តីសន្និដ្ឋាននោះផ្អែកទៅលើរបាយការណ៍របស់អ្នកជំនាញវេជ្ជសាស្ត្រឯករាជ្យដែលអង្គជំនុំជម្រះបានតែងតាំង ហើយដែលរបាយការណ៍នោះត្រូវបានលើកយកមកសួរដេញដោលយ៉ាងយូរនៅចំពោះមុខអង្គជំនុំជម្រះ រួមទាំងការសួរដេញដោលដោយមេធាវីការពារក្តី អៀង សារី ផងដែរ។ នៅខែ មីនា ឆ្នាំ ២០១៣ អ្នកជំនាញវេជ្ជសាស្ត្រឯករាជ្យដែលអង្គជំនុំជម្រះបានតែងតាំងនឹងវាយតម្លៃសាជាថ្មីទៅលើសម្បទារបស់ អៀង សារី ក្នុងការចូលរួមសវនាការ។ នាពេលនេះ អង្គជំនុំជម្រះបានស្នើសុំឱ្យក្រុមគ្រូពេទ្យដែលមានភារកិច្ច ពិនិត្យ ព្យាបាល និងថែទាំ អៀង សារី ផ្តល់នូវរបាយការណ៍ជាលាយលក្ខណ៍អក្សរជាប្រចាំថ្ងៃ និងជូនដំណឹងពីការប្រែប្រួលសំខាន់ៗនៃស្ថានភាពសុខភាពរបស់ អៀង សារី មកអង្គជំនុំជម្រះ។ អង្គជំនុំជម្រះពិចារណាឃើញថា នេះគឺជាវិធីសាស្ត្រសមស្របទៅនឹងកាលៈទេសៈបច្ចុប្បន្ន។

៤. សំណើរបស់មេធាវីការពារក្តីដែលសុំឱ្យក្រុមគ្រូពេទ្យដែលមានភារកិច្ចពិនិត្យ ព្យាបាល និងថែទាំ អៀង សារី ផ្តល់យោបល់បន្ថែមលើស្ថានភាពសុខភាពរបស់ អៀង សារី នោះ សំដៅដល់សំណើ

សុំឱ្យមានការវាយតម្លៃបន្តពីសម្បទារបស់គាត់ក្នុងការចូលរួមសវនាការ។ ប៉ុន្តែ ស្របពេលជាមួយគ្នានោះ មេធាវីការពារក្តីបង្ហាញថា ក្រុមគ្រូពេទ្យទាំងនោះពុំមានគុណវុឌ្ឍិក្នុងការវាយតម្លៃទៅលើការសន្និដ្ឋានរបស់អ្នកជំនាញដែលថា អៀង សារី មានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការទៅវិញ។ក្នុងបរិបទនេះ និងដោយផ្អែកលើភស្តុតាងរបស់អ្នកជំនាញនោះ នាពេលថ្មីៗនេះ អង្គជំនុំជម្រះបានសន្និដ្ឋានថា ជនជាប់ចោទ អៀង សារី អាចចូលរួមក្នុងកិច្ចដំណើរការនីតិវិធីជាធម្មតាបាន។ ការណ៍ដែលអង្គជំនុំជម្រះបង្គាប់ឱ្យក្រុមគ្រូពេទ្យដែលមានភារកិច្ច ពិនិត្យ ព្យាបាល និងថែទាំជនជាប់ចោទ ជូនដំណឹងពីការប្រែប្រួលសំខាន់ៗនៃស្ថានភាពសុខភាពរបស់ អៀង សារី គឺដើម្បីធានាថា អង្គជំនុំជម្រះបានទទួលព័ត៌មានគ្រប់គ្រាន់។

៥. អ្នកជំនាញឯករាជ្យត្រូវបានតែងតាំងរួចហើយ ដើម្បីវាយតម្លៃពីសមត្ថភាពរបស់ អៀង សារី ក្នុងការចូលរួមសវនាការ ហើយការវាយតម្លៃនាពេលបន្ទាប់ក៏នឹងត្រូវធ្វើឡើងនៅ ខែ មីនា ឆ្នាំ ២០១៣ នេះដែរ។ មេធាវីការពារក្តីបានស្នើសុំឱ្យអង្គជំនុំជម្រះតែងតាំងអ្នកជំនាញវេជ្ជសាស្ត្រដែលមានគុណវុឌ្ឍិមកពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីផ្តល់នូវការវាយតម្លៃប្រចាំថ្ងៃជាបន្តបន្ទាប់ចំពោះសមត្ថភាពរបស់ អៀង សារី ក្នុងការចូលរួមកិច្ចដំណើរការនីតិវិធីសវនាការ នៅពេលគាត់ស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ តែសំណើនេះក៏ត្រូវបានបដិសេធដែរ។ ការវាយតម្លៃបន្ថែមទៀតដោយវេជ្ជបណ្ឌិតមកពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ត្រឹមតែធ្វើឱ្យត្រួតគ្នាទៅលើការរៀបចំដែលមានស្រាប់ប៉ុណ្ណោះ។ អង្គជំនុំជម្រះនឹងពិចារណាទៅលើការវាយតម្លៃរបស់អ្នកជំនាញចំពោះសម្បទារបស់ អៀង សារី និងអនុសាសន៍នានាថាតើការវាយតម្លៃនាពេលអនាគតចាំបាច់នឹងត្រូវធ្វើឱ្យបានញឹកញាប់កម្រិតណានោះ។